សេចក្តីប្រកាសព័ត៌មាន

សម្រាប់ការចេញផ្សាយបន្ទាន់

# សញ្ញាវិជ្ជមានឆ្ពោះទៅរកការកើនឡើងចំនួនអណ្តើកហ្លួង ក្នុងដែនជម្រកធម្មជាតិ

**ខេត្តកោះកុង (ថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៨)** - បន្ទាប់ពីការលែង **អណ្តើកហ្លួង** កាលពីខែវិច្ឆិកា ឆ្នាំ២០១៧ នៅតាមប្រព័ន្ធព្រៃកស្រែអំបិល ក្រុមការងារតាមដាន និងស្រាវជ្រាវរបស់អង្គការសមាគមអភិរក្សសត្វព្រៃ (WCS) និងនាយកដ្ឋានអភិរក្សជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបញ្ជាក់ថាកិច្ចខិតខំប្រឹងប្រែងក្នុងការអភិរក្សអណ្តើកហ្លួងដែលជាប្រភេទសត្វជិតផុតពូជបំផុតក្នុងសកលលោកកំពុងបង្ហាញសញ្ញានៃភាពជោគជ័យ។ ឆ្លងតាមការតាមដានរៀងរាល់ខែដោយក្រុមល្បាតសហគមន៍ រដ្ឋបាលជលផល និងអង្គការ WCS បានរកឃើញអណ្តើកហ្លួងទាំងអស់ក្នុងរយៈពេល១០ខែបន្ទាប់ពីលែងតាមរយៈឧបករណ៍តាមដានដែលបានបំពាក់លើស្នូកអណ្តើកហ្លួង។ ទិន្នន័យពីការស្រាវជ្រាវ និងតាមដានបានបង្ហាញថាអណ្តើកហ្លួងចំនួន១ក្បាលបានផ្លាស់ទីទៅកាន់ប្រព័ន្ធព្រៃកជីផាត់ដែលមានចម្ងាយជិត១០០គីឡូម៉ែត្រពីទីតាំងលែង។ ដោយឡែក អណ្តើកហ្លួងចំនួន១ក្បាលផ្សេងទៀតត្រូវបានប្រជានេសាទប្រទះឃើញជាប់មង និងបានប្រគល់ឱ្យអង្គការ WCS ដើម្បីថែរក្សា។ លទ្ធផលទាំងនេះបានបញ្ជាក់ថាអណ្តើកហ្លួងទាំងអស់បាន និងកំពុងផ្លាស់ទីទៅកាន់ទីជម្រកនានាបន្ទាប់ពីការលែង។

**អណ្តើកហ្លួង** ស្ថិតនៅក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ជាប្រភេទរងគ្រោះជិតផុតពូជបំផុត និងស្ថិតក្នុងចំណោមអណ្តើកទាំង២៥ប្រភេទដែលកំពុងរងគ្រោះថ្នាក់ខ្លាំងជាងគេបំផុតនៅលើពិភពលោក និងចាត់ជាប្រភេទកំពុងរងគ្រោះថ្នាក់ក្នុងប្រទេសកម្ពុជា។ ជាពិសេស ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៤៩ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៥ បានដាក់បញ្ចូលសត្វអណ្តើកហ្លួងនេះជាប្រភេទសត្វល្អនតំណាងឱ្យប្រទេសកម្ពុជា។

សត្វអណ្តើកហ្លួងធ្លាប់ត្រូវបានគេគិតថាបានផុតពូជពីប្រទេសកម្ពុជាទៅហើយ ប៉ុន្តែនៅក្នុងឆ្នាំ២០០០ រដ្ឋបាលជលផល និងអង្គការ WCS បានសិក្សាស្រាវជ្រាវ និងរកឃើញមានចំនួនសត្វអណ្តើកប្រភេទនេះដ៏តិចតួចឡើងវិញនៅតាមប្រព័ន្ធព្រៃកស្រែអំបិលក្នុងប្រទេសកម្ពុជា។ ចាប់តាំងពីពេលនោះមក អង្គការ WCS និងរដ្ឋបាលជលផលបានធ្វើការរួមគ្នាការពារ និងអភិរក្សសត្វអណ្តើកហ្លួងទាំងនេះពីការផុតពូជតាមរយៈសកម្មភាព៖ ការការពារសំបុកពងកូន ការចិញ្ចឹម និងថែរក្សា ការពង្រឹងការអនុវត្តច្បាប់ ការទប់ស្កាត់បទល្មើសនេសាទ និងការជួញដូរសត្វព្រៃ ការស្រាវជ្រាវ និងការតាមដាន។

**លោក សោម ស៊ីថា** ទីប្រឹក្សាបច្ចេកទេសគម្រោងអភិរក្សប្រចាំខេត្តកោះកុងនៃអង្គការ WCS បានលើកឡើងថា៖ "កម្មវិធីការពារសំបុកពងកូនដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារសត្វអណ្តើកហ្លួងពីការផុតពូជ ម្យ៉ាងវិញទៀត កម្មវិធីនេះបានផ្តល់ការងារដល់អតីតអ្នកប្រមូលពងដើម្បីការពារសំបុកដែលអាចបង្កើនប្រាក់ចំណូលបន្ថែមសម្រាប់ពួកគាត់ ជាពិសេសដើម្បីធានាថាពងកូនអណ្តើកហ្លួងត្រូវបានការពារយ៉ាងយកចិត្តទុកដាក់ និងភ្ញាស់ដោយជោគជ័យ។"

លោក ស៊ីថា បានបន្តថា៖ "ក្នុងឆ្នាំ២០១៥ និងឆ្នាំ២០១៧ គម្រោងបានព្រលែងអណ្តើកហ្លួងជំទង់ញី និងឈ្មោល ពីរក្រុមដែលមានចំនួនស្មើៗគ្នាទៅក្នុងជម្រកធម្មជាតិវិញដោយមានបំពាក់ឧបករណ៍តាមដាន។ កម្មវិធីតាមដានក្រោយការព្រលែងបានបង្ហាញពីភាពជោគជ័យដោយរកឃើញអត្រារស់រានមានជីវិតរបស់អណ្តើកហ្លួងដែលព្រលែងមានកម្រិតខ្ពស់តាមរយៈការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើកត្តាគំរាមកំហែងនានា។ យើងសង្ឃឹមថា អណ្តើកដែលព្រលែងទាំងនេះនឹងធ្វើការបន្តពូជនាពេលដ៏ខ្លីខាងមុខដែលជាក្តីសង្ឃឹមក្នុងការស្តារឡើងវិញនូវប្រភេទសត្វដ៏កម្រនេះ។"

**លោក អ៊ុក វិបុល** ប្រធាននាយកដ្ឋានអភិរក្សជលផលនៃរដ្ឋបាលជលផលក៏បានគូសបញ្ជាក់ផងដែរថា៖ "សកម្មភាពបូមខ្សាច់ ការកាប់បំផ្លាញព្រៃលិចទឹកដែលជាទីជម្រក និងការនេសាទខុសច្បាប់បានបង្កការគំរាមកំហែងដល់ទីជម្រករបស់អណ្តើកហ្លួងជាពិសេសតំបន់ឆ្នេរខ្សាច់ដែលជាជម្រកពងកូន។ យើងត្រូវការការគាំទ្រពីស្ថាប័នពាក់ព័ន្ធនានាដើម្បីចូលរួមកាត់បន្ថយហានិភ័យដែលកើតមានឡើងនៅតាមប្រព័ន្ធព្រែកស្រែអំបិល។"

លោក អ៊ុក វិបុល បានបន្តថា៖ "រដ្ឋបាលជលផលកំពុងរៀបចំសេចក្តីព្រាងប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីដាក់តំបន់មួយចំនួនធំនៅតាមប្រព័ន្ធព្រែកស្រែអំបិលទៅជាតំបន់គ្រប់គ្រងសម្រាប់សត្វអណ្តើកហ្លួង និងក្រពើត្រី។ សេចក្តីប្រកាសនេះនឹងចូលជាធរមានក្នុងពេលឆាប់ៗនេះ។"

អង្គការ WCS សូមថ្លែងអំណរគុណដល់ម្ចាស់ជំនួយដូចជា Wildlife Reserves Singapore, Turtle Survival Alliance, National Geographic Society, Chicago Zoological Society, US Forest Service, Rainforest Trust និង Critical Ecosystem Partnership Fund ដែលបានផ្តល់ថវិកាគាំទ្រដល់ការងារអភិរក្សសត្វអណ្តើកហ្លួងកន្លងមក។

**សម្រាប់ព័ត៌មានបន្ថែម៖**

លោក គុជ សុវិទ្យា
មន្ត្រីផ្នែកទំនាក់ទំនង និងសារព័ត៌មាន
អង្គការសមាគមអភិរក្សសត្វព្រៃនៅកម្ពុជា (WCS)
ទូរស័ព្ទ៖ ០៧៧ ៧៧ ០២ ៧៧
អ៊ីម៉ែល៖ skuch@wcs.org